

# សិក្ខាសាលាជាតិ

## ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០នៃគណៈកម្មាធិការជាតិ
## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

រាជធានីភ្នំពេញ សាលប្រជុំក្រសួងមហាផ្ទៃ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩

# សកម្មភាពជាអាទិភាពនៃ ផ.ស.ថ. ឆ្នាំ២០២០
# របស់ គ.ជ.អ.ប.

បង្ហាញដោយ ៖ លេខាធិការដ្ឋាន គ.ជ.អ.ប.

# មាតិកា

១. សេចក្ដីសង្ខេបអំពីផអពទី៣ (២០១៨-២០២០)

២. សកម្មភាពជាអាទិភាពនៃ ផ.ស.ថ. ឆ្នាំ២០២០

៣. ថវិកាប៉ាន់ស្មាននៃ ផ.ស.ថ. ឆ្នាំ២០២០

# ១. សេចក្ដីសង្ខេបអំពីផអពទី៣

# (២០១៨-២០២០)

# ១. សេចក្តីសង្ខេបអំពីផអ៣ទី៣

❖ កម្មវិធីជាតិ១០ឆ្នាំត្រូវបានបែងចែកជា៣ដំណាក់កាលសម្រាប់ការអនុវត្ត

| ផអ៣ទី១ ៖ ២០១១-២០១៤ | ផអ៣ទី២ ៖ ២០១៥-២០១៧ | ផអ៣ទី៣៖ ២០១៨-២០២០ |
|---|---|---|
| ការអភិវឌ្ឍគោលនយោបាយ ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីកែលំអគុណភាពសេវា និងការអភិវឌ្ឍមូលដ្ឋាន | ការបន្តជំរុញ និងពង្រឹងការទទួលខុសត្រូវ និងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការ ផ្តល់សេវា និងការអភិវឌ្ឍ មូលដ្ឋាន |

❖ ផអ៣ទី៣ គឺជាផែនការអនុវត្តដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិ

# ១. សេចក្តីសង្ខេបអំពីដអពាទី៣ (ត)

## គោលបំណងចម្បងនៃផអពាទី៣

រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានស្វ័យភាព និង គណនេយ្យភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

# ១. សេចក្តីសង្ខេបអំពីផអពទី៣ (ត)

## គោលដៅនៃផអពទី៣ ៖

- ពង្រឹងការគ្រប់គ្រងការងារកំណែទម្រង់របស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងអភិបាលកិច្ចល្អរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- លើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស
- ជំរុញការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្តួចផ្តើមគំនិតប្រកបដោយភាពច្នៃប្រឌិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅ មុខងារដែលបានផ្ទេរ និងមុខងារដទៃទៀត
- បង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។

# ២. សកម្មភាពចម្បងនៃ ផ.ស.ថ ឆ្នាំ២០២០

# ការរៀបចំសកម្មភាពនៃ ផ.ស.ថ. ឆ្នាំ២០២០

សកម្មភាពនៃ ផ.ស.ថ. ឆ្នាំ២០២០ ត្រូវបានរៀបចំដោយផ្អែកលើ ៖

- សមាសភាគ និងលទ្ធផលរំពឹងទុកនានានៃ ផអ៣ទី៣
- សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តបន្តពីឆ្នាំ២០១៩ និងត្រូវការរយៈពេលអនុវត្តន៍ច្រើនឆ្នាំ ដើម្បីសម្រេចបាននូវសកម្មភាពទាំងនេះ។ ភាគច្រើននៃសកម្មភាពទាំង៣៩ ជាសកម្មភាពដែលត្រូវបន្តពីឆ្នាំ២០១៩។
- ជាសកម្មភាពថ្មីក្នុងផអ៣ទី៣ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០១៩ ដូចជាការរៀបចំតាក់តែងកម្មវិធីជាតិដំណាក់កាលបន្ទាប់ ការរៀបចំផអ៣ទី១ នៃកម្មវិធីជាតិដំណាក់កាលបន្ទាប់ ការរៀបចំសេចក្តីណែនាំស្តីពីការវាយតម្លៃរួមគ្នាលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ល។

# សេចក្តីសង្ខេបអំពី ផ.ស.ថ. ឆ្នាំ២០២០

## ចង្កោមសកម្មភាព និងសកម្មភាពនៃ ផ.ស.ថ. ឆ្នាំ២០២០

| ល.រ. | ចង្កោមសកម្មភាព | សកម្មភាព | សកម្មភាពជាអាទិភាព |
|---|---|---|---|
| ១ | ការគ្រប់គ្រងការងារកំណែទម្រង់ | ២២ | ៨ |
| ២ | អភិបាលកិច្ចល្អ | ២៣ | ៧ |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | ៩ | ៣ |
| ៤ | ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន | ៤០ | ១៧ |
| ៥ | វិមជ្ឈការហិរញ្ញវត្ថុ | ៥ | ៤ |
| សរុប | | ៩៩ | ៣៩ |

# ការកំណត់សកម្មភាពជាអាទិភាពទាំង៣៩

សកម្មភាពជាអាទិភាពទាំង៣៩នេះ ត្រូវបានកំណត់ចេញពីសកម្មភាពជាចម្បងទាំង៩៩ ដោយផ្អែកលើសកម្មភាពចម្បងទាំងឡាយណាដែលមានអាទិភាពខ្ពស់ និងត្រូវផ្តោតការយកចិត្តទុកដាក់ និងដោះស្រាយក្នុងឆ្នាំនីមួយៗដូចជា ៖

- ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធរបស់អង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការអនុវត្តគោលនយោបាយវិមជ្ឈការ
- ការរៀបចំលិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលពាក់ព័ន្ធនឹងការផ្ទេរ និងអនុវត្តមុខងារដែលបានផ្ទេរ រួមទាំងកិច្ចដំណើរការការិយាល័យច្រកចេញចូលតែមួយ
- ការរៀបចំកម្មវិធីជាតិដំណាក់កាលបន្ទាប់ និងផែនការអនុវត្តរយៈពេលបីឆ្នាំ
- ជាសកម្មភាពដែលពាក់ព័ន្ធនឹងបញ្ហាអន្តរវិស័យដូចជា ការលើកកម្ពស់បរិយាប័ន្ននិងសមធម៌សង្គម គណនេយ្យភាព ការពង្រឹងយន្តការសម្រុះសម្រួលបណ្តឹង...។ល។
- ការបង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ សម្រាប់ការផ្តល់សេវា និងកិច្ចអភិវឌ្ឍមូលដ្ឋាន រួមទាំងការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

# សកម្មភាពជាអាទិភាពទាំង៣៩

១. ការកែសម្រួលរចនាសម្ព័ន្ធរបស់អង្គភាពនានានៃក្រសួងមហាផ្ទៃ និងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីធានាដល់ការគាំទ្រ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

២. ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធរបស់រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក

៣. ការរៀបចំកម្មវិធីជាតិដំណាក់កាលបន្ទាប់

៤. ការរៀបចំ ផអ៣ទី១ នៃកម្មវិធីជាតិដំណាក់កាលបន្ទាប់

៥. ការរៀបចំ និងការដាក់បញ្ចូលសកម្មភាពស្នូលនៃកំណែទម្រង់ទៅក្នុងផែនការសកម្មភាព និងថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

# សកម្មភាពជាអាទិភាពទាំង៣៩ (ត)

៦. ការរៀបចំសកម្មភាពនានានៃការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកកម្ពស់ចំណេះដឹង និងការយល់ដឹងរបស់សាធារណជនអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

៧. ការរៀបចំបែបផែននានានៃភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្ដល់សេវា និងការអភិវឌ្ឍមូលដ្ឋាន

៨. ការពង្រីក និងការពង្រឹងការងារគណនេយ្យភាពសង្គមក្នុងក្រុង ស្រុកគោលដៅចំនួន១៤៣

៩. ការពង្រឹង និងការពង្រីកការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងក្រុង ស្រុក ខណ្ឌទាំងអស់

# សកម្មភាពជាអាទិភាពទាំង៣៩ (ត)

១០. ការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីអធិការកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

១១. ការរៀបចំក្របខ័ណ្ឌវាយតម្លៃការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១២. ការរៀបចំកិច្ចដំណើរការស្តីពីការពិនិត្យមើលរួមគ្នាប្រចាំឆ្នាំនូវប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១៣. ការគ្រប់គ្រង និងកិច្ចដំណើរការនៃប្រព័ន្ធទិន្នន័យព័ត៌មានសម្រាប់ការគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ ដោយរដ្ឋបាលក្រុង ស្រុក

១៤. ការអនុវត្តកម្មវិធីស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

១៥. ការអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាព និងការបង្កើនចំណេះដឹងរបស់ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិអំពីបរិយាប័ន្ន និងសមធម៌សង្គម

# សកម្មភាពជាអាទិភាពទាំង៣៩ (ត)

១៦. ការពង្រឹងគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់ការគ្រប់គ្រងធនធានមនុស្ស តាមបែបវិមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយថ្នាក់ជាតិ

១៧. ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុកក្នុងការបំពេញការងារ និងការទទួលខុសត្រូវរបស់ខ្លួន

១៨. សាលាជាតិរដ្ឋបាលមូលដ្ឋានផ្តល់សេវាអភិវឌ្ឍសមត្ថភាព ផ្អែកតាមផែនការអនុវត្តរបស់ខ្លួន

១៩. ការពិនិត្យ និងការកែសម្រួលលិខិតបទដ្ឋានសម្រាប់លើកកម្ពស់ការអនុវត្តមុខងារជាអាណត្តិទូទៅ

២០-៣៤. ការគាំទ្ររដ្ឋបាលក្រុង និងរដ្ឋបាលស្រុកក្នុងការអនុវត្តមុខងារដែលបានផ្ទេរពីក្រសួង ស្ថាប័ននានា ស្របតាមរចនាសម្ព័ន្ធថ្មីដូចមុខងារវិស័យអប់រំ សុខាភិបាល បរិស្ថាន សង្គមកិច្ច អភិវឌ្ឍន៍ជនបទ ធនធានទឹក សាធារណៈការ ទេសចរណ៍ កសិកម្ម វប្បធម៌ ។ល។

# សកម្មភាពជាអាទិភាពទាំង៣៩ (ត)

៣៥. ការពង្រឹង និងការពង្រីកកិច្ចដំណើរការនៃការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌចំនួន១២១

៣៦. ការពិនិត្យ និងការកែសម្រួលការវិភាជធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលក្រុង ស្រុក

៣៧. ការពិនិត្យ និងការកែសម្រួលប្រព័ន្ធចែករំលែកធនធានហិរញ្ញវត្ថុពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក

៣៨. ការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរ

៣៩. ការរៀបចំ និងការអនុវត្តគម្រោងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ៣. ថវិកាប៉ាន់ស្មាននៃ ផ.ស.ថ. ឆ្នាំ២០២០

# ថវិកាប៉ាន់ស្មាននៃ ផ.ស.ថ. ឆ្នាំ២០២០

| ល.រ. | ចង្កោមសកម្មភាព | ថវិកា (លានរៀល) |
|---|---|---|
| ១ | ការគ្រប់គ្រងការងារកំណែទម្រង់ | 7,407 |
| ២ | អភិបាលកិច្ចល្អ | 39,696 |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | 2,251 |
| ៤ | ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន | 151,825 |
| ៥ | វិមជ្ឈការហិរញ្ញវត្ថុ | 3,330,486 |
| សរុប | | **3,531,665** |

# ថវិកាប៉ាន់ស្មាននៃ ផ.ស.ថ. ឆ្នាំ២០២០

| ល.រ. | ប្រភេទថវិកា | រាជរដ្ឋាភិបាល | ដៃគូអភិវឌ្ឍ | សរុប (លានរៀល) |
|---|---|---|---|---|
| ១ | ធនធានហិរញ្ញវត្ថុផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ | 3,304,904 | 117,264 | **3,422,167** |
| ២ | សកម្មភាពកំណែទម្រង់ស្នូល | 34,455 | 35,097 | **69,552** |
| ៣ | គម្រោង កម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍ | 6,829 | 33,118 | **39,946** |
| សរុប | | **3,346,187** | **185,478** | **3,531,665** |

# ថវិកាប៉ាន់ស្មាននៃ ផ.ស.ថ. ឆ្នាំ២០២០

## ធនធានហិរញ្ញវត្ថុផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ. | រដ្ឋបាលថ្នាក់ក្រោមជាតិ | ថវិការដ្ឋ | ថវិកាដៃគូ | សរុប ( លានរៀល ) |
|---|---|---|---|---|
| ១ | រាជធានី ខេត្ត | 2,262,899 | 0 | 2,262,899 |
| ២ | ក្រុង ស្រុក ខណ្ឌ | 238,688 | 22,480 | 261,168 |
| ៣ | ឃុំ សង្កាត់ | 803,317 | 94,784 | 898,101 |
| | សរុប | **3,304,904** | **117,264** | **3,422,167** |

# ថវិកាថ៉ាន់ស្មាននៃ ផ.ស.ថ. ឆ្នាំ២០២០ (ត)

## ថវិកាគាំទ្រការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២០ របស់ក្រសួង ស្ថាប័ន

| ល.រ. | ក្រសួង ស្ថាប័ន | ថវិកា (លានរៀល) | ល.រ. | ក្រសួង ស្ថាប័ន | ថវិកា (លានរៀល) |
|---|---|---|---|---|---|
| ១ | លេខាធិការដ្ឋាន គ.ជ.អ.ប. | 9,500 | ១៣ | ក្រសួងអភិវឌ្ឍន៍ជនបទ | 0 |
| ២ | ក្រសួងមហាផ្ទៃ | 936 | ១៤ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 0 |
| ៣ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 144 | ១៥ | ក្រសួងរ៉ែ និងថាមពល | 119 |
| ៤ | ក្រសួងផែនការ | 197 | ១៦ | ក្រសួងពាណិជ្ជកម្ម | 164 |
| ៥ | ក្រសួងមុខងារសាធារណៈ | 123 | ១៧ | ក្រសួងធនធានទឹក និងឧតុនិយម | 20 |
| ៦ | ក្រសួងកិច្ចការនារី | 161 | ១៨ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 110 |
| ៧ | ក្រសួងអប់រំ យុវជន និងកីឡា | 600 | ១៩ | ក្រសួងគ្រប់គ្រងដែនដី | 115 |
| ៨ | ក្រសួងសង្គមកិច្ច | 0 | ២០ | ក្រសួងកសិកម្ម | 165 |
| ៩ | ក្រសួងបរិស្ថាន | 466 | ២១ | ក្រសួងការងារ | 20 |
| ១០ | ក្រសួងសុខាភិបាល | 205 | | | |
| ១១ | ក្រសួងសាធារណៈការ | 205 | | | |
| ១២ | ក្រសួងទេសចរណ៍ | 187 | | | |
| សរុប | | | | | **13,438** |

# ថវិកាប៉ាន់ស្មាននៃ ផ.ស.ថ. ឆ្នាំ២០២០ (ត)

## ថវិកាគាំទ្រការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២០ របស់រាជធានី ខេត្តរួមបញ្ចូលក្រុង ស្រុក ខណ្ឌ

| ល.រ. | រាជធានី ខេត្ត | ថវិកា (លានរៀល) | ល.រ. | រាជធានី ខេត្ត | ថវិកា (លានរៀល) |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | 412 | ១៣ | ព្រះវិហារ | 285 |
| ២ | បាត់ដំបង | 0 | ១៤ | ព្រៃវែង | 297 |
| ៣ | កំពង់ចាម | 2,451 | ១៥ | ពោធិ៍សាត់ | 421 |
| ៤ | កំពង់ឆ្នាំង | 889 | ១៦ | រតនគិរី | 272 |
| ៥ | កំពង់ស្ពឺ | 301 | ១៧ | សៀមរាប | 868 |
| ៦ | កំពង់ធំ | 1,369 | ១៨ | ព្រះសីហនុ | 0 |
| ៧ | កំពត | 1,936 | ១៩ | ស្ទឹងត្រែង | 778 |
| ៨ | កណ្តាល | 2,491 | ២០ | ស្វាយរៀង | 975 |
| ៩ | កោះកុង | 149 | ២១ | តាកែវ | 835 |
| ១០ | ក្រចេះ | 849 | ២២ | ឧត្តរមានជ័យ | 774 |
| ១១ | មណ្ឌលគិរី | 735 | ២៣ | កែប | 68 |
| ១២ | ភ្នំពេញ | 1,223 | ២៤ | ប៉ៃលិន | 216 |
| | | | ២៥ | ត្បូងឃ្មុំ | 920 |
| សរុប | | | | | **19,512** |

# ថវិកាប៉ាន់ស្មាននៃ ជ.ស.ថ. ឆ្នាំ២០២០ (ត)

## ថវិកានៃគម្រោង កម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍ

| ល.រ | គម្រោង កម្មវិធីនានា | ដៃគូអភិវឌ្ឍ | ថវិកាផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ថវិកាគាំទ្រការងារកំណែទម្រង់ | សរុប (លានរៀល) |
|---|---|---|---|---|---|
| ១ | ការអភិវឌ្ឍសមត្ថភាពដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន | ADB | 0 | 0 | 0 |
| ២ | ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូច ដំហានទី២ | ADB | 43,144 | 15,905 | **59,050** |
| ៣ | ការគាំទ្រមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | ADB | 22,000 | 1,880 | **23,880** |
| ៤ | ការគាំទ្រការងារគណនេយ្យភាពសង្គម តាមរយៈកញ្ចប់ថវិការួម | WB | 0 | 6,870 | **6,870** |
| ៥ | ការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច | WB | 31,607 | 1,672 | **33,279** |
| ៦ | ការលើកកម្ពស់អាហារូបត្ថម្ភ | WB | 5,520 | 1,960 | **7,480** |
| ៧ | កម្មវិធីអភិវឌ្ឍសហគមន៍ (កម្មវិធីសិទ្ធិកុមារ) | UNICEF | 280 | 600 | **880** |
| ៨ | ការពង្រឹងសិទ្ធិអំណាចស្ត្រីដើម្បីសង្គមធន់នឹងការប្រែប្រួលអាកាសធាតុ | UNEP | 200 | 400 | **600** |
| ៩ | កាត់បន្ថយភាពរងគ្រោះនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ | UNDP | 0 | 1,343 | **1,343** |
| ១០ | ការបង្កើតបរិយាកាសអំណោយផលប្រកបដោយចីរភាព | UNDP | 0 | 120 | **120** |
| ១១ | ការលើកកម្ពស់ប្រព័ន្ធស្បៀងមូលដ្ឋានប្រកបដោយនិរន្តរភាព | WFP | 480 | 202 | **682** |
| ១២ | ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ដំណាក់កាលទី៣ | GIZ | 0 | 0 | **0** |
| ១៣ | កម្មវិធីកំណែទម្រង់រដ្ឋបាលបែបវិមជ្ឈការ | GIZ | 0 | 5,683 | **5,683** |
| ១៤ | ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ | IFAD | 14,032 | 5,232 | **19,264** |
| ១៥ | ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងព្រៃឈើនៅក្នុង និងជុំវិញតំបន់ព្រៃឡង់ | USAID | 0 | 0 | **0** |
| ១៦ | ការពង្រឹងការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ | CSOs | 0 | 25,321 | **25,321** |
| ១៧ | ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ | JICA | 0 | 448 | **448** |
| ១៨ | ការពង្រឹងតួនាទីសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | NACPC | 0 | 233 | **233** |
| ១៩ | ការពង្រឹងតួនាទីសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន | NLLC | 0 | 251 | **251** |
| | សរុប | | **117,264** | **68,120** | **185,383** |

# សូមអរគុណ!